## ៦-កិច្ចវេរសង្ឃភត្ត

**-អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ** *បពិត្រព្រះគម្ពែងសង្ឃ ដ៏ចំរើនអើយ រីចង្ហាន់បិណ្ឌបាត នៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌,*

**មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស** *យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើម,*

**-ឥមំ (សង្ឃភត្តំ) សបរិក្ខារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម** *យើងខ្ញុំទាំងឡាយសូម (វេរនូវសង្ឃភត្តនេះ) ព្រមទាំងបរិក្ខារ ប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធរូបស្នងព្រះអង្គជាប្រធាន*

**-តេ គុណវន្តានយោ ឥមំ (សង្ឃភត្តំ) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន** *សូមលោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើមនោះ សំគាល់នូវ (សង្ឃភត្ត)នេះ ថាដូចជារបស់នៃខ្លួនហើយ សូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយសូមឲ្យរួចរំដោះចាកទុក្ខទោសនិងពៀរវេរាទាំងពួង ឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ ៣ប្រការ គឺៈ សម្បត្តិមនុស្ស១ សម្បត្តិទេវតា១ សម្បត្តិព្រះនិព្វាន១ ដោយសមគួរ តាមសេចក្តីប្រាថ្នា របស់លោកអ្នកដ៏មានគុណ ទាំងឡាយនោះចុះ ដោយអំណាចផលានិសង្សដែលហូរជូនទៅ មិនដាច់នេះហោង។*

**-ទុតិយម្បិ...។** *-អស់វារៈពីរដងផង... ។*

**-តតិយម្បិ...។** *-អស់វារៈបីដងផង... ៕*

*វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ " ← " ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។*